**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

តុលាការកំពូល
សភាផ្នែករដ្ឋប្បវេណី
សំណុំរឿង លេខៈ១៥៤
ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៨
<u>សាលដីកា</u>
លេខៈ៣១
ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម **ឌិត មុន្នី** ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក **ប៉ែន ស៊ុន** ជាចៅក្រម
៣-លោក **វៀល មួន** ជាចៅក្រមរបាយការណ៍
៤-លោក **ជីវ កេង** ជាចៅក្រម
៥-លោក **ស៊ិន ឌឹម** ជាចៅក្រម

<u>**ក្រឡាបញ្ជី**</u>

-លោក **សុង ម៉ៅ**

<u>**តំណាងមហាអយ្យការ**</u>

-លោក **ជួន ស៊ុនឡេង** ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមិនា ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៧៣ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះហែម ឈន អាយុ៤៩ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅភូម៣ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនៈគីរី ។ ឪពុកឈ្មោះប្រាក់ ពឹក(រ) ម្តាយឈ្មោះសៀក(ស) ប្រពន្ធឈ្មោះទំ អ៊ាន មានកូន០៦នាក់ ។

និងចុងបណ្តឹងសាទុក្ខឈ្មោះធន អៀម ភេទស្រី អាយុ៦៥ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅភូមិ១ ឃុំឡាបានសៀក ស្រុកបានលុង ខេត្តរតនៈគីរី ។ ឪពុកឈ្មោះធន (ស) ម្តាយឈ្មោះគឹម ទូច(ស) ប្តីឈ្មោះសេង មានកូន០២នាក់ ។

<u>**កម្មវត្ថុបណ្តឹង**</u> ប្តឹងទាមទារដី ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ របស់ឈ្មោះហែម ឈន ប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៥៤ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

ពាក្យបណ្តឹងចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៥ របស់ឈ្មោះធន អៀម ប្តឹងពីឈ្មោះហែម ឈន រំលោភលើដីធ្លីកម្មសិទ្ធិរបស់ខ្លួនដោយសំអាងហេតុថា ឈ្មោះហែម ឈន ក្រោយពីមានការព្រមព្រៀងជាមួយឈ្មោះសុង ហើយសង់ផ្ទះលើដីរបស់ខ្លួន ។ ខ្លួនសំណូមពរទាមទារដីរបស់ខ្លួនព្រោះដីនេះខ្លួនមានប័ណ្ណកម្មសិទ្ធិរួចហើយ ។

បានឃើញសាលក្រមលេខ០៣ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ របស់តុលាការខេត្តរតនៈគីរី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលស្គាល់ពាក្យបណ្តឹងរបស់អ្នកស្រីធន អៀម ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-លោកធន់ ប៊ុនសុង ត្រូវចេញប្រាក់ចំនួន១០០.០០០(ដប់ម៉ឺនរៀល) ឱ្យទៅលោក ហែម ឈន វិញ ។

៣-លោកហែម ឈន ត្រូវរុះផ្ទះចេញពីដីដែលមានទំនាស់ រួចប្រគល់ឱ្យទៅអ្នកស្រីធន អៀម កាន់កាប់ជាកម្មសិទ្ធិស្របច្បាប់តទៅ ។

ธ ៤-សាលក្រមនេះជំនុំជំរះដាសាធារណៈចំពោះមុខគូក្តី

៥-បើកផ្លូវឱ្យប្តឹងឧទ្ធរណ៍រយៈពេល២ខែគិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ៧៣ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៩៧ ប្តឹងមិនសុខចិត្តលើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី១១-០៧-១៩៩៦ របស់ដើមបណ្តឹងឧទ្ធរណ៍ ឈ្មោះហែម ឈន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី២៨-០៥-១៩៩៦ របស់តុលាការ ខេត្តរតនៈគីរី ទុកជាបានការ ។

៣-សម្រេចកាត់យកប្រាក់ប្រដាប់ក្តីនៅដាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វឹង២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និងលើអាជ្ញាធរតុលាការ៥.០០០រៀល ។

- កាលបើសាលដីកានេះចូលជាស្ថាពរហើយ បង្គាប់ឱ្យឈ្មោះហែម ឈន បង់ពន្ធសមាមាត្រ១% លើប្រាក់១០០.០០០រៀល ។ ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ៨០% និងដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៤- សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី ។

-សម្រេចបើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២-០៣-៩៨ របស់លោកហែម ឈន ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាការពាររបស់ឈ្មោះហែម ឈន ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៨ ។

បានឃើញសារណាតបរបស់ឈ្មោះធន អៀម ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៩៨ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយករណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជំរះបានតាមច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់សារណារបស់ឈ្មោះហែម ឈន នៅពេលជំនុំជំរះ ។

បានស្តាប់សារណាតបរបស់ឈ្មោះធន អៀម នៅពេលជំនុំជំរះ ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថាបណ្តឹងសាទុក្ខលេខ៥៧ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨ របស់លោកហែម ឈន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថាការណ៍ដែលលោកហែម ឈន អះអាងថា ប័ណ្ណសម្គាល់សិទ្ធិលេខC១_១៧៥ ចុះថ្ងៃទី១៤-០១-៩៤ របស់លោកធន់ ប៊ុនហៀង ជាប័ណ្ណកម្មសិទ្ធិក្លែងបន្លំនោះ ពុំមានភស្តុតាងណាបញ្ជាក់គួរឱ្យជឿបានឡើយហើយការសំអាងទៅលើគណៈកម្មការវាស់វែងដែលថាក្នុងការវាស់ដីឱ្យលោកធន់ ប៊ុនហៀង គឺធ្វើចាប់ពីបារ៉ែតទៅក្រោយនោះ ក៏ជាការពុំត្រឹមត្រូវដែរ ពីព្រោះថាពាក្យសុំចុះថ្ងៃទី១៥-០៧-៩០ របស់លោកធន់ ប៊ុនហៀង បានកំណត់ព្រំខាងលិច ទល់នឹងថ្នល់ដែរ ដូច្នេះដីដែលលោកហែម ឈន សង់ផ្ទះនោះ ជាដីដែលស្ថិតក្នុងប័ណ្ណកម្មសិទ្ធិលេខC១-១៧៥ ប្រាកដមែន ។

-យល់ឃើញថាការណ៍ដែលតុលាការខេត្តរតនៈគិរីក៏ដូចសាលាឧទ្ធរណ៍ដែរ ដែលសំរេចឱ្យលោកធន់ ប៊ុន សុង សងប្រាក់ចំនួន១០០.០០០រៀល ទៅលោកហែម ឈន នោះជាការខុសឆ្គង ពីព្រោះថា

សាលាជំរះទាំងពីរនេះពុំបានចាត់របៀបបញ្ចូលលោកធន់ ប៊ុនសុង មកក្នុងរឿងក្តីនេះផង និងពុំមានពាក្យសុំពីគូក្តីណាមួយផង ។

- យល់ឃើញថា គូភាគីនៃរឿងក្តីនេះបានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២.០៣.៩៨ ដែលសម្រេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ លើកលែងចំណុចទី២ នៃសាលក្រមលេខ០៣ ចុះថ្ងៃទី២៨.០៥.៩៨ របស់តុលាការខេត្តរតនៈគីរី ដែលត្រូវទុកជាមោឃៈ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីកំបាំងមុខគូក្តី ប៉ុន្តែចាត់ទុកជាចំពោះមុខ**

១- ទទួលបណ្តឹងសាទុក្ខលេខ៥៧ ចុះថ្ងៃទី១២-០៣-៩៨ របស់លោកហែម ឈន ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ៩៥ ចុះថ្ងៃទី១២.០៣.៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងចំណុចទី២ នៃសាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី២៨.០៥.៩៦ របស់តុលាការខេត្តរតនៈគីរី ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១៥៤ ចុះថ្ងៃទី២២.០៥.៩៨ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញត្រង់ចំណុចទី២ នៃសាលក្រមរដ្ឋប្បវេណីលេខ០៣ ចុះថ្ងៃទី២៨.០៥.៩៦ របស់តុលាការខេត្តរតនៈគីរី ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលលោកហែម ឈន បានបង់រួចហើយគឺ ៖

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

- ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ។

-បង្គាប់ឱ្យលោកហែម ឈន បង់ពន្ធសមាមាត្រមួយភាគរយលើតម្លៃដីទំនាស់ ។

៥- សាលដីកានេះប្រកាសនាសវនាការ ជាសាធារណៈនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៩ ។